# SAN DIEGO CITY SCHOOLS

EUGENE BRUCKER EDUCATION CENTER
4100 Normal Street, San Diego, CA 92103-2682

(619) 725-5506

**Carl A. Cohn**
អគ្គស្នងការក្រសួងអប់រំប្រចាំក្រុង


ខែ កញ្ញា ឆ្នាំ ២០០៧

មាតាបិតា និងអ្នកអាណាព្យាបាលសិស្សជាទីរាប់អាន,

ស្វាគមន៍មាតាបិតា និងសិស្សចូលរៀនទាឆ្នាំ ២០០៧-០៨ នេះ។ សិស្ស និងគ្រូសារបានវិញត្រឡប់មកចូលរៀនវិញ ហើយយើងសូមអរគុណដល់លោកអ្នកដែលផ្តល់ការអនុញ្ញាតិ និងទុកចិត្តដល់យើងធ្វើការបំរើដល់កូនលោកអ្នកសិក្សា។

ការចាប់ផ្តើមទាឆ្នាំសិក្សាថ្មីនេះគឺជាគំនិតដើម្បីផ្តល់បេសកកម្មដើម្បី:

- បង្កើនការសិក្សារបស់សិស្សអោយបានល្អតលាស់
- ផ្តល់សន្តិសុខ, របៀបរៀបរយ និងរក្សាសាលារៀនអោយបានល្អ
- ពង្រឹងការទាក់ទងរវាងមាតាបិតា, សហគមន៍, ហាងជំនួញទូទៅដើម្បីផ្តល់ការអប់រំសិស្សឲ្យបានខ្ពស់
- ផ្តល់សីលធម៌បុគ្គលិកការងារល្អ ព្រមទាំង
- ផ្តល់ថវិការដល់សាលារៀនទាំងអស់ឲ្យបានគ្រប់គ្រាន់។

ខ្ញុំមានសេចក្តីរីករាយសូមជម្រាបថា យើងកំពុងតែប្រតិបត្តិកិច្ចការរបស់យើងឲ្យបានសម្រេចតាមគោលការទាំងនេះ។ សិស្សសាលារៀនប្រចាំ San Diego បន្តការប្រឹងប្រែងសិក្សាបានប្រសើរជាងក្រសួងអប់រំទាំងអស់នៅក្នុងរដ្ឋ California។ ដំណើរការរបស់យើងឆ្ពោះទៅចំគោលដៅ ប៉ុន្តែយើងត្រូវតែប្រឹងប្រែងអោយបានខ្លាំងដើម្បីទទួលផលប្រយោជន៍ និងបំបាត់នូវផលវិបាកមួយចំនួន។ ដើម្បីជួយដោះស្រាយនូវបញ្ហានេះ យើងមានគម្រោងកម្មវិធីសិក្សា និងបង្រៀនសំរាប់ប្រតិបត្តិនារដូចស្លឹកឈើធ្លាក់នេះ។ គម្រោងនេះធ្វើឡើងដើម្បីសម្រេចតាមគោលការយ៉ាងខ្ពស់ទាំងអស់, បង្កើងគោលការបង្រៀនឲ្យបានល្អ, យុទ្ធវិធីដើម្បីជួយសិស្សគ្រប់រូបធ្វើការសិក្សាអោយបានជោគជ័យ, ប្រើប្រាស់ប្រព័នការសិក្សាឲ្យបានត្រឹមត្រូវព្រមទាំងណែនាំលោកគ្រូ-អ្នកគ្រូ និងចាងហ្វាងអោយមានឯកទេសណែនាំសិស្សបានល្អប្រសើរ។

យើងនឹងបន្តការស្តាប់ដល់មាតាបិតានូវអ្វីដែលគាត់ចង់បាន និងត្រូវការដើម្បីជួយដល់សិស្សសិក្សា។ ទម្រង់លិខិតស្រាវជ្រាវសំរាប់មាតាបិតាឆ្លើយផ្តល់ជាយោបល់-មតិបានផ្ញើជូនដល់គាត់កាលពីខែ មិថុនា។ សូមអរគុណដល់លោកអ្នកដែលបានចំណាយពេលវេលាបំពេញទម្រង់ស្រាវជ្រាវនោះ ហើយបានផ្ញើត្រឡប់មកវិញ។ យើងនៅតែបន្តការសិក្សាស្រាវជ្រាវ ប៉ុន្តែយើងមានសេចក្តីរីករាយដោយបានឃើញថា មាតាបិតាចំនួន៩០ភាគរយបានឆ្លើយថា សាលារៀនរបស់យើងមានសន្តិសុខ ព្រមទាំងមានអារម្មណ៏ថា គាត់បានទទួលស្វាគមន៍ ពេលអញ្ជើញទៅសាលារៀន។

សាលរៀនថ្មីចំនួន ប្រាំ បានបើកទ្វាបំរើសិស្សជាលើកទីមួយនាថ្ងៃទី ៤ ខែ កញ្ញា នេះ។ យើងបានព្យាយាមរក្សាថវិការដើម្បីជួយផ្តល់ដល់សាលារៀនធ្វើការគ្រប់គ្រងសាលារៀនឲ្យបានល្អ ទោះជារដ្ឋមានបញ្ហាថវិការ និងចំនួនសិស្សចូលរៀនមានចុះថយក្តី។ យោងទៅតាមទម្រង់លិខិតស្រាវជ្រាវថ្មីៗស្តីអំពី បុគ្គលិកការងារបង្ហាញអោយឃើញថា បុគ្គលិកការងារភាគច្រើនមានសីលធម៌ល្អ ឬល្អជាទីបំផុត។

យើងព្យាយាមប្រតិបត្តិឲ្យបានសម្រេច ហើយពេលនេះកិច្ចការរបស់យើងមិនបានចប់នៅឡើយ។ ជាមួយនឹងការគាំទ្រ និងការចូលរួមរបស់លោកអ្នក យើងនឹងស្ថាបនាគោលការណ៏ណែនាំសិស្សឲ្យបានជ័យជំនះ ដើម្បីឲ្យក្រសួងអប់រំប្រចាំក្រុងរបស់យើងក្លាយទៅជាក្រសួងអប់រំប្រចាំក្រុងដ៏ល្អប្រសើរបំផុតនៅក្នុងសហរដ្ឋអាមេរិកនេះ។

សូមអរគុណដល់លោកអ្នកដែលអនុញ្ញាតិអោយធ្វើការបំរើសិស្ស និងលោកអ្នកជាមាតាបិតា។ សូមឲ្យឆ្នាំសិក្សានេះមានដំណើរការល្អជាទីបំផុត!

ដោយក្តីរាក់ទាក់បំផុត

Carl A. Cohn
អគ្គស្នងការក្រសួងអប់រំប្រចាំក្រុង